សុន្ទរកថារបស់**លោក គូរ៉ូមីយ៉ា តាកាយ៉ូស៊ី**

ទីប្រឹក្សាស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ

សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ របស់ប្រទេសជប៉ុន

២៦ កុម្ភៈ ២០១៣

- **សូមគោរព លោក ស៊ើយ វង្សស៊ី នាយកមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែង!**
- **សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយដែលបានចូលរួមក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងសាងសង់អគារពិសោធន៍វិទ្យាសាស្ត្រជាមួយអ្នកតំណាងនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែង។ ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងដែលការចុះហត្ថលេខានេះត្រូវបានធ្វើឡើងក្នុងឱកាសដ៏ពិសេសនៃឆ្នាំ២០១៣ ដែលជាខួបអនុស្សាវរីយ៍ទី៦០នៃទំនាក់ទំនងមិត្តភាពជប៉ុន-កម្ពុជា។

គម្រោងនេះមានគោលដៅកែលម្អបរិស្ថានបណ្តុះបណ្តាលសម្រាប់គរុសិស្សនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែងតាមរយៈការសាងសង់អគារពិសោធន៍វិទ្យាសាស្ត្រថ្មីមួយ ព្រមទាំងការបំពាក់សង្ហារឹម និងបរិក្ខារចាំបាច់មួយចំនួន។ ថវិកាជំនួយដែលផ្តល់ជូនសម្រាប់គម្រោងនេះមានចំនួន៥២,៧០០ដុល្លាអាមេរិក។ យើងរំពឹងថាគម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់គរុសិស្សប្រមាណ ៣០០ នាក់ដែលនឹងក្លាយជាគ្រូបង្រៀននៅសាលាបឋមសិក្សានានាក្នុងខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគីរី និងខេត្តរតនគីរីក្រោយពេលបញ្ចប់វគ្គបណ្តុះបណ្តាល។ តាមរយៈការកែលម្អសមត្ថភាព និងបច្ចេកទេសបង្រៀនរបស់លោកគ្រូ-អ្នកគ្រូ យើងក៏រំពឹងផងដែរថា សិស្សានុសិស្សកម្រិតបឋមសិក្សាប្រមាណ៦៣,០០០នាក់នៅក្នុងខេត្តទាំងនេះនឹងទទួលបានការអប់រំផ្នែកវិទ្យាសាស្ត្រកាន់តែប្រសើរ ដោយហេតុនេះ សន្តិសុខមនុស្សជាតិសម្រាប់ប្រជាជនងាយរងគ្រោះក៏ត្រូវបានកែលម្អផងដែរ។

ការអប់រំ និង អភិវឌ្ឍន៍ធនធានមនុស្សជាមូលដ្ឋានគ្រឹះសម្រាប់អភិវឌ្ឍន៍ប្រទេសកម្ពុជានាពេលអនាគត។ ដោយហេតុនេះហើយ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពខ្ពស់ទៅលើវិស័យអប់រំដោយចាត់ទុកជាមុំមួយក្នុងបណ្តាមុំទាំងបួននៃយុទ្ធសាស្ត្រចតុកោណសម្រាប់អភិវឌ្ឍន៍ជាតិ។

ដោយទទួលស្គាល់ពីសារៈសំខាន់នៃវិស័យអប់រំក្នុងប្រទេសកម្ពុជា រដ្ឋាភិបាលជប៉ុនបានផ្តល់ការគាំទ្រទាំងផ្នែកសម្ភារៈ និងផ្នែកបច្ចេកទេសដែលរួមទាំងការផ្តល់ការបណ្តុះបណ្តាលដល់គ្រូវិទ្យាសាស្ត្រនៅតាមសាលាគរុកោសល្យភូមិភាគ និងខេត្តតាំងពីឆ្នាំ២០០៨ដល់ឆ្នាំ២០១២ជាដើម។ គម្រោងដែលទើបត្រូវបានចុះកិច្ចសន្យានៅថ្ងៃនេះផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយកម្មវិធីបណ្តុះបណ្តាលដែលបានរៀបរាប់ខាងលើ ហើយយើងរំពឹងថាការរួមបញ្ចូលគ្នាទាំងផ្នែករឹង និងផ្នែកទន់នេះនឹងផ្តល់ប្រសិទ្ធភាពកាន់តែប្រសើរ។

ខ្ញុំសង្ឃឹមថាគម្រោងដែលចុះហត្ថលេខាថ្ងៃនេះនឹងត្រូវបានអនុវត្តដោយរលូន និង ប្រសិទ្ធភាព ព្រមទាំងថែទាំយ៉ាងត្រឹមត្រូវដោយដៃគូរបស់យើងគឺមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែងដើម្បីគ្រូបង្រៀនជាច្រើននាពេលអនាគត និងសិស្សរបស់ពួកគេអាចទទួលបានអត្ថប្រយោជន៍ពីគម្រោងនេះ។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមថាគម្រោងនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។ សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!